ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**នាយកក្រុមហ៊ុន ឌីអេហ្វអេស (ខេមបូឌា) លីមីធីត**


លេខបញ្ជីពាណិជ្ជកម្ម ៖ ០០០០៣៩៨៩
លេខអត្តសញ្ញាណសហគ្រាសក្នុង ប.ស.ស៖ ១០០៧៨០០៥
អាសយដ្ឋាន ៖ ផ្ទះលេខ ៩៦៨ វិថីហ្សាលឌីហ្គោល ក្រុម៦ ភូមិ
សាលាកន្សែង សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប
លេខទូរសព្ទ ៖០៨៦៨៥០០២៩-អ៊ីមែល(E-mail)៖Sovanna.Chhorn@dfs.com


**សូមគោរពជូន**
**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**តាមរយៈ** ៖ លោកប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តសៀមរាប

**កម្មវត្ថុ** ៖ សំណើរសុំព្យួរកិច្ចសន្យាការងារ កម្មករនិយោជិតចំនួន ១៩៤នាក់ រយៈពេល៥សប្តាហ៍ ចាប់ពីថ្ងៃទី០១ ខែឧសភា ឆ្នាំ២០២០ ដល់ថ្ងៃទី ០៥ ខែមិថុនា ឆ្នាំ២០២០

សេចក្តីដូចបានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាបថា ដើម្បីចូលរួមបង្ការការឆ្លងរាតត្បាតនៃជម្ងឺរលាកផ្លូវដង្ហើមកូវីត១៩ ក៏ដូចជាការពារសុវត្ថិភាពដល់បុគ្គលិក និងភ្ញៀវរបស់យើង ក្រុមហ៊ុនយើងខ្ញុំស្នើសុំព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន១៩៤នាក់ (ស្រី ១១៩នាក់ និងប្រុស ៧៥នាក់) រយៈពេល៥សប្តាហ៍ចាប់ពីថ្ងៃទី០១ ខែឧសភា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី ០៥ ខែមិថុនា ឆ្នាំ២០២០។

ក្នុងរយៈពេលនៃការព្យួរកិច្ចសន្យាការងារ ក្រុមហ៊ុនបានព្រមព្រៀងផ្តល់ប្រាក់ខែជូន កម្មករនិយោជិតចំនួន៦០%នៃប្រាក់ខែគោល។

សេចក្តីដូចបានជំរាបជូនខាងលើសូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាត្រួតពិនិត្យនិងសម្រេចដោយអនុគ្រោះ។ សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ។

ថ្ងៃអង្គារ ទី ២៨ ខែមេសា ឆ្នាំ២០២០
ហត្ថលេខា និងត្រា
នាយកក្រុមហ៊ុន
ក្រេក លេធីស
**Craig Lettice**

ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន ឌីអេហ្វអេស (ខេមបូឌា) លីមីធីត DFS (CAMBODIA) LIMITED KINGDOM OF CAMBODIA

**ភ្ជាប់មកជាមួយ:**
- កិច្ចព្រមព្រៀងអំពីនិតិវិធីទូទាត់ជាមួយកម្មករនិយោជិត ៣ច្បាប់
- បញ្ជីរាយនាមកម្មករនិយោជិតដែលស្នើសុំព្យួរកិច្ចសន្យាការងារ ចំនួន ៣ច្បាប់
- បញ្ជីបើកប្រាក់ឈ្នួលចុងក្រោយមុនពេលស្នើសុំព្យួរកិច្ចសន្យាការងារ
- វិញ្ញាបនបត្រពាណិជ្ជកម្មចំនួន ៣ច្បាប់
- ប័ណ្ណពន្ធប៉ាតង់ចំនួន ៣ច្បាប់
- វិញ្ញាបនបត្របញ្ជិកាសហគ្រាស គ្រឹះស្ថានក្នុង ប.ស.ស ចំនួន៣ច្បាប់

DFS

ក្រុមនិយោជិតព្យួរកិច្ចសន្យាការងារ (មិនបំពេញការងារ)

កាលបរិច្ឆេទ

ឈ្មោះ៖
លេខអត្តសញ្ញាណបុគ្គលិក៖

# កិច្ចព្រមព្រៀងអំពីតិវិធីទូទាត់ជាមួយកម្មករនិយោជិក

ជូនចំពោះ [ឈ្មោះបុគ្គលិក]

ដូចបានពិភាក្សាជាមួយអ្នកកន្លងមក ក្រុមហ៊ុនកំពុងប្រឈមមុខនឹងកាលៈទេសៈដ៏លំបាក ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ដែលបានជះឥទ្ធិពលដល់អាជីវកម្មរបស់ក្រុមហ៊ុនទាំងមូល នៅទូទាំងពិភពលោក។ ក្រុមហ៊ុនត្រូវកាត់បន្ថយចំណាយប្រតិបត្តិការផ្សេងៗ រហូតដល់ពេលស្ថានភាពសេដ្ឋកិច្ចមានភាពប្រសើរឡើង។ ដោយឈរលើមូលដ្ឋានដើម្បីបញ្ចៀសការបន្តបញ្ឈប់និយោជិតទូទាំងក្រុមហ៊ុន ក្រុមហ៊ុនសូមធ្វើការស្នើសុំដល់និយោជិតក្នុងការជួយចូលរួមកាត់បន្ថយការចំណាយ ដោយយល់ព្រមកាត់បន្ថយប្រាក់ខែគោលរបស់អ្នកជាបណ្តោះអាសន្ន។

នេះជាការសម្រេចចិត្តដ៏លំបាកបំផុតមួយ ខណៈពេលដែលក្រុមហ៊ុនយល់ពីផលប៉ះពាល់ដែលនឹងជះឥទ្ធិពលដល់អ្នក ប៉ុន្តែការសម្រេចនេះគឺជាជម្រើសដែលល្អបំផុតនៅពេលនេះ ដើម្បីការពារហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាពេលអនាគត និងការពារការងាររបស់និយោជិត។ ក្រុមហ៊ុនរំពឹងលើការគាំទ្ររបស់អ្នកដើម្បីជួយក្រុមហ៊ុនក្នុងអំឡុងពេលដ៏លំបាកនេះ ហើយនឹងធ្វើការវាយតម្លៃស្ថានភាពឡើងវិញនៅក្នុងរយៈពេលបួនខែខាងមុខ។

យើងខ្ញុំសូមថ្លែងអំណរគុណ ចំពោះការឯកភាពរបស់អ្នកលើការកែប្រែកិច្ចសន្យាការងាររបស់អ្នក ចុះថ្ងៃទី [កាលបរិច្ឆេទ] ("**កិច្ចសន្យាការងារ**") ដូចមានសង្ខេបខាងក្រោម៖

១. ប្រាក់ខែគោលរបស់អ្នកនឹងត្រូវកាត់បន្ថយចំនួន ៥០% ដោយចាប់ផ្តើមអនុវត្តចាប់ពីថ្ងៃទី ០៦ ខែឧសភា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០២០ សម្រាប់រយៈពេលមួយខែ ("**ផែនការ**")។

២. អ្នកនឹងបន្តទទួលបានអត្ថប្រយោជន៍ និងប្រាក់ឧបត្ថម្ភដូចមានក្នុងពេលបច្ចុប្បន្នដដែល ទៅតាមគោលការណ៍សមាមាត្រដោយផ្អែកលើថ្ងៃធ្វើការ។

៣. ការទូទាត់តាមច្បាប់ណាមួយ (ដូចជាប្រាក់ឈ្នួលថ្ងៃឈប់សម្រាកដែលកំណត់ច្បាប់ ការឈប់សម្រាកឈឺ ការឈប់សម្រាកលំហែមាតុភាព ឬបិតុភាព) នឹងត្រូវបានផ្តល់ស្របតាមលក្ខខណ្ឌតម្រូវដោយច្បាប់។ ការចូលរួមវិភាគទានសម្រាប់មូលនិធិសោធន ឬការចូលនិវត្តន៍នឹងត្រូវធ្វើឡើងស្របតាមលក្ខខណ្ឌច្បាប់ផងដែរ។

៤. អ្នកមិនតម្រូវឱ្យចូលរួម ឬអនុវត្តការងារក្នុងអំឡុងពេលនេះទេ តែអ្នកត្រូវអនុវត្តតាមការរៀបចំផ្សេងៗរបស់អាជ្ញាធរមូលដ្ឋាន និងការរឹតត្បិតផ្សេងៗទាក់ទងនឹងជំងឺកូវីដ-១៩។

៥. ក្នុងករណីដែលក្រុមហ៊ុនចាប់ផ្តើមប្រតិបត្តិការអាជីវកម្មមុនកាលកំណត់ អ្នកនឹងឯកភាព និងគាំទ្រដល់ក្រុមហ៊ុនដើម្បីត្រលប់មកធ្វើការវិញតាមការស្នើរបស់ក្រុមហ៊ុន។

៦. ក្នុងអំឡុងពេលនៃការព្យួរកិច្ចសន្យាការងារ និយោជិតត្រូវបង្ហាញខ្លួនជានិច្ចតាមការហៅរបស់ក្រុមហ៊ុន ហើយដើម្បីដោះស្រាយស្ថានភាពពិសេសណាមួយ និយោជិតមួយចំនួនអាចត្រូវបានតម្រូវឱ្យមកបំពេញការងារម្តងម្កាល ស្របតាមការចាត់ចែងរបស់ក្រុមហ៊ុន ដោយមានការជូនដំណឹងជាមុនយ៉ាងតិច ២៤ ម៉ោង។ ការចាត់ចែងទាក់ទងនឹងសំណងសម្រាប់ថ្ងៃដែលនិយោជិតតម្រូវឱ្យមកធ្វើការ នឹងត្រូវស្ថិតនៅក្រោមការរៀបចំរវាងនិយោជិត និងក្រុមហ៊ុន។

លើកលែងតែការកែប្រែក្នុងលិខិតនេះ ខ និងលក្ខខណ្ឌផ្សេងៗទៀតនៅក្នុងកិច្ចសន្យាការងារនឹងរក្សានៅដដែល។

ប្រសិនបើផែនការខាងលើ តម្រូវឲ្យមានការកែប្រែមុនថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២០ ឬមានការពន្យារពេល ក្រុមហ៊ុននឹងធ្វើការប្រកាសបន្ថែមទៀតតាមពេលវេលាសមស្រប។ ដូច្នេះនិយោជិតទាំងអស់ចាំបាច់តម្រូវឱ្យរក្សាទំនាក់ទំនង តាមរយៈអ៊ីម៉ែល និងទូរស័ព្ទចល័ត ដើម្បីទទួលបានព័ត៌មានទាន់ពេលវេលាពីក្រុមហ៊ុន។

សូមចុះហត្ថលេខា និងប្រគល់លិខិតនេះមួយច្បាប់មកដល់ក្រុមហ៊ុន ឱ្យបានមុនថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២០ ដើម្បីបញ្ជាក់ពីការឯកភាពរបស់អ្នកចំពោះការកែប្រែលក្ខខណ្ឌការងាររបស់អ្នកដូចបានរៀបរាប់ខាងលើ។ ប្រសិនបើអ្នកមានសំណួរ សូមទាក់ទងលោកស្រី ឈន សុវណ្ណា ប្រធានផ្នែកធនធានមនុស្សតាមរយៈ Sovanna.Chhorn@dfs.com។

ដោយក្តីរាប់អាន

លោក Craig Lettice

នាយកក្រុមហ៊ុន DFS (Cambodia) Limited

DFS

ខ្ញុំ ____________________ សូមបញ្ជាក់ថាខ្ញុំបានអានយ៉ាងយកចិត្តទុកដាក់ និងយល់ច្បាស់ពី ខ និងលក្ខខណ្ឌ និងខ្លឹមសារផ្នែកច្បាប់នៃលិខិតនេះ និងដោយពិចារណាលើការបន្តការងាររបស់ខ្ញុំ ជាមួយក្រុមហ៊ុន DFS (Cambodia) Limited(“**ក្រុមហ៊ុន**”) ខ្ញុំសូមយល់ព្រមចំពោះការផ្លាស់ប្តូរលក្ខខណ្ឌក្នុងកិច្ចសន្យាការងាររបស់ខ្ញុំ ដូចមានចែងក្នុងលិខិតនេះ។ ខ្ញុំសូមទទួលស្គាល់ និងយល់ព្រមថា ប្រាក់ខែគោល និងអត្ថប្រយោជន៍នានាដែលក្រុមហ៊ុនផ្តល់ឱ្យខ្ញុំ ក្នុងអំឡុងពេលអនុវត្តផែនការខាងលើ គឺច្រើនជាងប្រាក់ខែអប្បបរមាដែលត្រូវបានធានាដោយច្បាប់ សម្រាប់ការចំណាយក្នុងការរស់នៅប្រចាំថ្ងៃក្នុងពេលបច្ចុប្បន្នរបស់ខ្ញុំ។

យើងខ្ញុំសូមចុះហត្ថលេខារបស់ខ្ញុំខាងក្រោម ដើម្បីបញ្ជាក់ពីកិច្ចព្រមព្រៀង និងការទទួលយករបស់យើងខ្ញុំ ចំពោះលក្ខខណ្ឌខាងលើ។

តំណាងប្រតិភូបុគ្គលិក

នាយកគ្រប់គ្រង

DFS (CAMBODIA) LIMITED
KINGDOM OF CAMBODIA

ស្នាមមេដៃ៖

កាលបរិច្ឆេទ៖